# មណ្ឌលដោះស្រាយវិបត្តិនៃការមានផ្ទៃពោះ

វិធីស្គាល់អំពីមណ្ឌលប្រឆាំងនឹងការយកកូនចេញ (Anti-Abortion Centers) ហើយនិងវិធីជៀសវាងទីកន្លែងទាំងនេះ

## តើមណ្ឌលដោះស្រាយវិបត្តិនៃការមានផ្ទៃពោះ (Crisis Pregnancy Centers/CPCs) គឺជាអ្វី?

- CPCs ហាក់បីដូចជាគ្លីនិកសម្រាប់អ្នកមានផ្ទៃពោះ ដែលផ្សព្វផ្សាយអំពីសេវាកម្មផ្នែកបន្តពូជគ្រប់ប្រភេទ ប៉ុន្តែ CPCs មិនមានផ្តល់ជូនការប្រឹក្សា ឬដំណើរការ ឬក៏ថ្នាំគ្រាប់សម្រាប់ការយកកូនចេញនោះទេ។
- គោលបំណងរបស់ CPCs ជាច្រើនគឺល្បួងអ្នកដែលមានផ្ទៃពោះមិនឱ្យយកកូនចេញ។
- CPCs ជាច្រើនគឺស្ថិតនៅជិតគ្លីនិកផ្នែកយកកូនចេញ ដោយចេតនា។ ការផ្សាយពាណិជ្ជកម្ម និងគេហទំព័រទាំងឡាយរបស់ពួកគេព្យាយាមធ្វើឱ្យអ្នកដែលអាចនឹងពិចារណាលើការយកកូនចេញនោះ មានភាពច្របូកច្របល់។

## សូមប្រយ័ត្នចំពោះសញ្ញាព្រមានទាំងនេះ នៅពេលកំពុងស្វែងរកសេវាកម្មផ្នែកការយកកូនចេញ តាមអនឡាញ៖

**“Pregnancy Decision Consultation”(ការពិគ្រោះគ្នាអំពីការសម្រេចចិត្តទាក់ទងទៅនឹងការមានផ្ទៃពោះ)**
CPCs មានទំនោរទៅលើការផ្សាយពាណិជ្ជកម្មអំពីការធ្វើតេស្តពិនិត្យមើលថាមានផ្ទៃពោះឬទេ ដោយមិនគិតថ្លៃ - ហើយប្រសិនបើអ្នកទទួលការពិនិត្យនោះធ្វើតេស្តទទួលលទ្ធផលវិជ្ជមានថាមានផ្ទៃពោះមែន បុគ្គលិក CPC ព្យាយាមបញ្ចុះបញ្ចូលឱ្យពួកគេបន្តមានផ្ទៃពោះ ហើយសម្រាលកូននោះ។

**“Free Limited Ultrasound”(ការឆ្លុះអេកូដែលមានកម្រិត ដោយមិនគិតថ្លៃ)**
ទីតាំងមួយចំនួនផ្តល់ជូនការឆ្លុះអេកូដោយមិនគិតថ្លៃ ដែលជាញឹកញាប់គឺធ្វើឡើងដោយបុគ្គលិកដែលមិនបានទទួលការបង្ហាត់ត្រឹមត្រូវ ហើយជាចម្បងគឺប្រើប្រាស់មិនមែនដើម្បីជូនដំណឹងដល់អ្នកទទួលការពិនិត្យនោះទេ ប៉ុន្តែដើម្បីបោកបញ្ឆោតពួកគេមិនឱ្យពិចារណាលើការយកកូនចេញទៅវិញ។

**“Post Abortion Counseling”(ការប្រឹក្សាបន្ទាប់ពីការយកកូនចេញរួច)**
CPCs សន្មត់ថាការយកកូនចេញគឺជាការជួបប្រទះទៅនឹងភាពអវិជ្ជមានមួយ ហើយអ្នកដែលបានយកកូនចេញនោះត្រូវការឱ្យមានការប្រឹក្សា។ តាមការពិត មនុស្សភាគច្រើនមានអារម្មណ៍ថាធូរស្បើយក្នុងចិត្ត បន្ទាប់ពីការយកកូនចេញរួច។

**“Abortion Pill Reversal”(ដំណើរការធ្វើឱ្យថ្នាំគ្រាប់សម្រាប់យកកូនចេញលែងមានប្រសិទ្ធិភាព)**
CPCs ផ្សាយពាណិជ្ជកម្មអំពីសេវាកម្ម “reversal” (ការធ្វើឱ្យលែងមានប្រសិទ្ធិភាព ឬធ្វើឱ្យវិលត្រឡប់ថយក្រោយវិញ) ចំពោះការយកកូនចេញ។ ពិធីការនេះគឺមិនមានការគាំទ្រដោយវិទ្យាសាស្ត្រនោះទេ និងអាចបង្កគ្រោះថ្នាក់ដល់សុខភាព ផងដែរ។

March 2024 (Cambodian)

ABORTION SAFE HAVEN PROJECT
COUNTY OF LOS ANGELES Public Health

# សម្គាល់អំពីសញ្ញាព្រមានផ្សេងៗ




**(យើងខ្ញុំមិនធ្វើការយកកូនចេញ ឬទទួលឈ្មោះសម្រាប់ការយកកូនចេញនោះទេ។)**
បើទោះបីជាការយកកូនចេញស្ថិតនៅក្នុងបញ្ជីនៃសេវាកម្មដែលមានផ្តល់ជូនក៏ដោយ ការពិតនោះ CPC នេះមិនផ្តល់ជូនការយកកូនចេញនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺព្យាយាមបញ្ចុះបញ្ចូលបុគ្គលម្នាក់មិនឱ្យយកកូនចេញ។




គ្លីនិកផ្សេងៗដែលផ្សព្វផ្សាយអំពី **“Abortion Pill Reversal”** (ដំណើរការធ្វើឱ្យថ្នាំគ្រាប់សម្រាប់ការយកកូនចេញលែងមានប្រសិទ្ធិភាព) គឺទំនងយ៉ាងខ្លាំងជា CPCs។ ដំណើរការនេះគឺ **មិនមានការគាំទ្រពីវិទ្យាសាស្ត្រឡើយ**។ ពាក្យនានា ដូចជា "regret" (ការស្តាយក្រោយ) និង "grief" (ការសោកសៅ) ជាដើមដែលពាក់ព័ន្ធទៅនឹងការយកកូនចេញនោះ ក៏អាចនឹងជាសញ្ញាព្រមានមួយផងដែរ។

# ធនធានផ្សេងៗ

មនុស្សគ្រប់រូបសមគួរនឹងទទួលបានការថែទាំសុខភាពដែលមិនមានគំនិតអវិជ្ជមាន ការបៀតបៀន និងភាពអាម៉ាស់នោះទេ។ អ្នកទទួលការពិនិត្យទាំងឡាយមានសិទ្ធិទទួលបានការអប់រំដែលប្រកបទៅដោយព័ត៌មានពិត និងការថែទាំដែលផ្តោតទៅលើអតិថិជន ហើយដែលទាក់ទងទៅនឹងជម្រើសគ្រប់ប្រភេទនៃការមានផ្ទៃពោះផងដែរ។

**សម្រាប់ព័ត៌មានផ្នែកការយកកូនចេញដែលច្បាស់លាស់ និងដើម្បីស្វែងរកគ្លីនិកថែទាំសុខភាពបន្តពូជត្រឹមត្រូវមួយ សូមពិនិត្យមើល៖**

- LA County Abortion Safe Haven Resource Guide (សេចក្តីណែនាំអំពីធនធានទាក់ទងទៅនឹងទីកន្លែងដែលមានសុវត្ថិភាពចំពោះការយកកូនចេញនៅក្នុងខោនធី LA) នៅលើគេហទំព័រ៖ http://publichealth.lacounty.gov/owh/Abortion/MultilingualResources.htm

## ធ្វើការរាយការណ៍អំពី CPC មួយ

រដ្ឋ California មានការព្រួយបារម្ភអំពីសេវាកម្មផ្សេងៗផ្តល់ជូនដោយមណ្ឌលដោះស្រាយវិបត្តិនៃការមានផ្ទៃពោះទាំងឡាយដែលមិនគ្រប់លក្ខណៈ និងក្នុងសភាពដែលទំនងជានឹងនាំឱ្យយល់ខុស។ លោកអគ្គមេធាវី Bonta ជំរុញពលរដ្ឋ California ទាំងឡាយដែលកំពុងស្វែងរកសេវាកម្មផ្នែកសុខភាពបន្តពូជឱ្យធ្វើការស្រាវជ្រាវ មុនពេលធ្វើដំណើរទៅកាន់គ្លីនិកមួយ ដើម្បីស្វែងយល់អំពីជម្រើសនានានៃការយកកូនចេញរបស់ពួកគេ។

**ប្រសិនបើអ្នកបានទៅកាន់ CPC មួយ ហើយជឿជាក់ថាអ្នកបានរងគ្រោះ ឬក៏ជាគោលដៅនៃដំណើរការដែលជាការឆបោក ឬជាការនាំឱ្យយល់ខុស ឬជាការខុសច្បាប់នោះ សូមដាក់ពាក្យបណ្តឹងអំពីការមិនពេញចិត្តឱ្យបានភ្លាមៗ នៅលើគេហទំព័រ៖ https://oag.ca.gov/crisis-pregnancy-center-complaint។**


1. Designed to Deceive CPC Study. Genderjustice.us. Accessed October 12, 2023. https://www.genderjustice.us/work/designed-to-deceive-cpc-study/.
2. Kendall. Plannedparenthood.org. Accessed October 12, 2023. https://www.plannedparenthood.org/blog/what-are-crisis-pregnancy-centers.
3. The CPC Industry as a Surveillance Tool of the Post-Roe State. Genderjustice.us. Accessed October 12, 2023. https://www.genderjustice.us/wp-content/uploads/2022/02/Alliance_CPC_Report_Feb2022_UrgentBrief2-10-22.pdf.
4. Attorney General Bonta Issues Consumer Alert Warning Californians That Crisis Pregnancy Centers Do Not Offer Abortion or Comprehensive Reproductive Care. Oag.ca.gov. Accessed October 12, 2023. https://oag.ca.gov/news/press-releases/attorney-general-bonta-issues-consumer-alert-warning-californians-crisis.
5. Facts Are Important: Medication Abortion "Reversal" Is Not Supported by Science. acog.org. Accessed 10/11/2023. https://www.acog.org/advocacy/facts-are-important/medication-abortion-reversal-is-not-supported-by-science.




ABORTION SAFE HAVEN PROJECT
COUNTY OF LOS ANGELES
CALIFORNIA
COUNTY OF LOS ANGELES Public Health